**អតិបូជាសន្តមីកាអែល កាព្រីអែល និងរ៉ាហ្វាអែល ជាអគ្គទេវទូត**

**ពីព្រះសហគមន៍សន្តីម៉ារីញញឹម**

**ចំការទៀង ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១**

"**ទេវទូតបានជួយថែរក្សាយើង**"

បងប្អូនជាទីស្រឡាញ់
ថ្ងៃនេះ ដែលព្រះសហគមន៍ឱ្យយើងគោរពអគ្គទេវទូតដែលមាន សន្តមីកាអែល ដែលជាស្ដេចនៃទេវទូតទាំងឡាយ។ ដូចយើងបានស្ដាប់នៅក្នុងអត្ថបទទី១ មីកាអែលដែលបានយកឈ្នះមារសាតាំងឱ្យចេញពីស្ថានបរមសុខ ដើម្បីឱ្យមារសាតាំងឈប់រំខានមនុស្សលោក និងណែនាំឱ្យមនុស្សវង្វេងតទៅទៀត។

ថ្ងៃនេះយើងគោរពសន្តកាព្រីអែល ដែលជាអគ្គទេវទូតរបស់ព្រះជាម្ចាស់ ដោយបានណែនាំព្រះបន្ទូលរបស់ព្រះអង្គ។ ជាពិសេសដល់ព្រះនាងម៉ារី ឱ្យធ្វើជាមាតារបស់ព្រះជាម្ចាស់ ឱ្យធ្វើជាមាតារបស់ព្រះយេស៊ូ។

យើងមានសន្តរ៉ាហ្វាអែល ដែលជាអគ្គទេវទូតមួយរូបដែលថ្លែងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលជាព្រះអង្គម្ចាស់នៃក្រុមទេវទូតទាំងឡាយ។

ដូច្នេះ ថ្ងៃនេះយើងមើលឃើញថាព្រះយេស៊ូបានណែនាំឱ្យយើងស្គាល់ដល់ក្រុមទេវទូត ព្រះអង្គមានព្រះបន្ទូលថា "**ខ្ញុំសូមប្រាប់អ្នករាល់គ្នាឱ្យដឹងច្បាស់ថា អ្នករាល់គ្នានឹងឃើញផ្ទៃមេឃបើកចំហ ហើយមានពួកទេវទូតរបស់ព្រះជាម្ចាស់ចុះឡើងពីលើបុត្រមនុស្ស**"។ នៅក្នុងប្រពៃណីកាតូលិក ទេវទូតបានជួយថែរក្សាការពារយើង រៀងៗខ្លួនយើងមានទេវទូតមួយរូបដែលការពារថែរក្សាយើង។ នៅក្នុងចំណោមមីកាអែល កាព្រីអែល និងរ៉ាហ្វាអែល ជាទេវទូតដែលថ្លែងព្រះបន្ទូលរបស់ព្រះជាម្ចាស់ឱ្យយើងស្ដាប់ឮ ដើម្បីឱ្យយើងធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គម្ចាស់ជានិច្ច។

ដូច្នេះ ថ្ងៃនេះយើងអធិដ្ឋានដើម្បីឱ្យក្រុមទេវទូត ជាពិសេសមីកាអែល កាព្រីអែល និងរ៉ាហ្វាអែល ថែរក្សាជីវិតរបស់យើង ថែរក្សាពិភពរបស់យើង។ ឱ្យយើងរួមគ្នាយកឈ្នះសង្គ្រាម យកឈ្នះអំពើអាក្រក់ ជាពិសេសយកឈ្នះជំងឺកូវីដ-១៩ ដើម្បីឱ្យជីវិតរបស់យើងអាចទៅជាជីវិតដែលពោរពេញដោយសិរីរុងរឿងនៅក្នុងពន្លឺរបស់ព្រះយេស៊ូគ្រីស្ត។ អាម៉ែន៕

+ លោកអភិបាល **អូលីវីយេ ឆ្មីតហាស្លេ**
អភិបាលព្រះសហគមន៍កាតូលិកកម្ពុជា
ភូមិភាគភ្នំពេញ